Article
62

# អភិបាលកិច្ចឌីជីថល

គោលគំនិតនៃអភិបាលកិច្ចឌីជីថលបានលេចឡើង ស្របពេលជាមួយនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) នៅចុងសតវត្សរ៍ទី២០។ ស្ថាប័នទាំងអស់បានទទួលស្គាល់សក្តានុពលនៃបច្ចេកវិទ្យាឌីជីថលក្នុងការធ្វើឱ្យសកម្មភាព និងប្រតិបត្តិការរបស់ពួកគេមានភាពប្រសើរឡើង ដើម្បីកែលម្អសេវាកម្មរបស់ខ្លួន ទាំងសេវាសាធារណៈ និងសេវាផ្តល់ដោយវិស័យឯកជន ក៏ដូចជាបានដឹងពីហានិភ័យមួយចំនួនដែលបង្កដោយបច្ចេកវិទ្យា ដែលនាំឱ្យអភិបាលកិច្ចឌីជីថលពិតជាមានសារៈសំខាន់។ ក្នុងន័យនេះ អភិបាលកិច្ចឌីជីថល សំដៅលើរបៀបដែលរដ្ឋាភិបាល ស្ថាប័ន និងសង្គមស៊ីវិលធ្វើការសម្រេចចិត្ត និងគ្រប់គ្រងលើការប្រើប្រាស់នានានៅក្នុងបរិបទឌីជីថលនាពេលបច្ចុប្បន្ន ដែលធ្វើឱ្យមានតុល្យភាពរវាងនវានុវត្តន៍ និងការគ្រប់គ្រងហានិភ័យ ដើម្បីឱ្យការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលមានតម្លាភាព មានទំនួលខុសត្រូវ និងមានក្រមសីលធម៌។ អភិបាលកិច្ចឌីជីថលធានាថាបច្ចេកវិទ្យាឌីជីថលដំណើរការសម្រាប់បម្រើផលប្រយោជន៍ដល់មនុស្ស មិនមែនបង្កជាបញ្ហានាំឱ្យមានការខាតបង់នោះទេ ដោយជួយកសាងទំនុកចិត្តលើប្រព័ន្ធឌីជីថល ពង្រឹងស្ថាប័ន និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាពនៅក្នុងយុគសម័យឌីជីថល។ អភិបាលកិច្ចឌីជីថលមិនមែនគ្រាន់តែជាការការពារ និងបទប្បញ្ញត្តិប៉ុណ្ណោះទេ តែក៏អនុញ្ញាតឱ្យស្ថាប័ននានាជំរុញការច្នៃប្រឌិតផងដែរ ដោយដឹងថាធុរកិច្ចឌីជីថលរបស់ពួកគេត្រូវបានគាំទ្រដោយគោលនយោបាយ នីតិវិធី និងក្របខ័ណ្ឌសីលធម៌ដ៏រឹងមាំ ដែលនេះចូលរួមដល់ការអភិវឌ្ឍប្រកបដោយចីរភាព ស្ថិរភាពសង្គម និងបង្កើនភាពប្រកួតប្រជែង។

## I. ភាពខុសគ្នារវាងអភិបាលកិច្ចបែបប្រពៃណី និងអភិបាលកិច្ចឌីជីថល

អភិបាលកិច្ចសំដៅលើប្រព័ន្ធ រចនាសម្ព័ន្ធ និងដំណើរការទាំងមូលដែលប្រើប្រាស់ ដើម្បីដឹកនាំ និងគ្រប់គ្រងស្ថាប័ន ឬសង្គម។ អភិបាលកិច្ចត្រូវបានគេកំណត់អត្តសញ្ញាណថាអ្នកណាអាចធ្វើការសម្រេចចិត្ត អ្នកណាមានសិទ្ធិអំណាចធ្វើសកម្មភាព និងអ្នកណាទទួលខុសត្រូវចំពោះរបៀបដែលរដ្ឋាភិបាល ស្ថាប័ន និងសង្គមស៊ីវិល បានប្រព្រឹត្ត និងអនុវត្ត។

ទាំងនេះ គឺជាភាពខុសគ្នារវាងអភិបាលកិច្ចបែបប្រពៃណី និងអភិបាលឌីជីថល៖

### ▶ របៀបដំណើរការ

អភិបាលកិច្ចបែបប្រពៃណីពឹងផ្អែកលើដំណើរការដោយដៃ ដែលមានមូលដ្ឋានលើក្រដាសដែលជារឿយៗតម្រូវឱ្យមានវត្តមានផ្ទាល់នៅក្នុងការិយាល័យ។ ចំពោះអភិបាលកិច្ចឌីជីថលប្រើប្រាស់

ICT (បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង) ដើម្បីធ្វើស្វ័យប្រវត្តិកម្មដំណើរការការងារ និងធ្វើឱ្យការផ្តល់សេវាកម្មកាន់តែមានភាពងាយស្រួល តាមរយៈ ផតថលអនឡាញ (Online Portals) និងកម្មវិធីទូរសព្ទ។

### ▶ របៀបអន្តរកម្ម (Interaction Style)

ប្រព័ន្ធគ្រប់គ្រងបែបប្រពៃណីមានឋានានុក្រមតឹងរ៉ឹង ហើយការបញ្ចេញមតិនានា របស់ប្រជាពលរដ្ឋមិនអាចសាយភាយបានច្រើននោះទេ ដែលជាហេតុធ្វើឱ្យការបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលមានភាពខ្វះខាត។ ដោយឡែក អភិបាលកិច្ចឌីជីថល លើកកម្ពស់ការចូលរួម និងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងការធ្វើគោលនយោបាយ និងផ្តល់ជាមតិក្នុងពេលវេលាជាក់ស្តែងតាមរយៈថ្នាលឌីជីថល។

### ▶ ការគ្រប់គ្រងទិន្នន័យ និងតម្លាភាព

កំណត់ត្រាបែបប្រពៃណីត្រូវបានរក្សាទុកនៅក្នុងឯកសាររូបវន្ត (Physical Files) ដែលធ្វើឱ្យការតាមដាន និងការទទួលខុសត្រូវមានការលំបាក។ អភិបាលកិច្ចឌីជីថលប្រើប្រាស់ទិន្នន័យបើកចំហ (Open data), ប្លុកឆេន (Blockchain) និងបញ្ញាសិប្បនិម្មិត (AI) ដើម្បីផ្តល់កំណត់ត្រាបានរហ័ស និងទាន់ពេលវេលា ដែលនេះអាចកាត់បន្ថយអំពើពុករលួយ និងបង្កើនទំនុកចិត្តពីសាធារណជន។

### ▶ ដំណើរការក្នុងការសម្រេចចិត្ត

អភិបាលកិច្ចប្រពៃណីពឹងផ្អែកលើគំរូប្រវត្តិសាស្ត្រ និងសមត្ថភាពត្រិះរិះពិចារណាផ្ទាល់របស់បុគ្គលដើម្បីធ្វើការសម្រេចចិត្ត ដែលធ្វើឱ្យការសម្រេចចិត្តមិនសូវត្រឹមត្រូវ និងដំណើរការយឺត។ ចំណែកឯអភិបាលកិច្ចឌីជីថល ប្រើប្រាស់បច្ចេកវិទ្យាទំនើប ដូចជា AI និងទិន្នន័យធំជាដើម ដែលជួយឱ្យការសម្រេចចិត្តផ្អែកលើទិន្នន័យជាក់ស្តែង និងមានប្រសិទ្ធភាពជាងមុន។

## II. បច្ចេកវិទ្យាសំខាន់ៗដែលប្រើប្រាស់សម្រាប់ដំណើរការអភិបាលកិច្ចឌីជីថល

ការមកដល់នៃយុគសម័យឌីជីថល បានធ្វើការផ្លាស់ប្តូររបៀបរបប ដែលស្ថាប័នទាំងអស់បំពេញកិច្ចការងារ ជាពិសេសនៅក្នុងជួររដ្ឋាភិបាលផ្ទាល់តែម្តង។ បច្ចុប្បន្ននេះ ឧបករណ៍ឌីជីថលបានជួយសម្រួលដល់ការងារជាច្រើន ដូចជា ការទំនាក់ទំនងកាន់តែមានភាពរហ័សជាងមុន, ការដំណើរការទិន្នន័យបានកាន់តែប្រសើរ និងធ្វើឱ្យការគ្រប់គ្រងអភិបាលកិច្ចកាន់តែមានប្រសិទ្ធភាព។ ការរីកចម្រើនទាំងនេះមានសក្តានុពលក្នុងការកែលម្អអភិបាលកិច្ច ដោយធ្វើឱ្យប្រព័ន្ធកាន់តែមានតម្លាភាព និងមានភាពទទួលខុសត្រូវខ្ពស់ ដែលនេះគឺជាភាពចាំបាច់ដែលមិនអាចខ្វះបានទាំងសម្រាប់ប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍។ ទាំងនេះជាបច្ចេកវិទ្យាសំខាន់ៗមួយចំនួន ដែលបានជួយក្នុងការគាំទ្រអភិបាលកិច្ចឌីជីថល៖

- **Open Data Platforms៖** ទិន្នន័យបើកចំហអនុញ្ញាតឱ្យរដ្ឋាភិបាលចែករំលែកព័ត៌មានសាធារណៈដោយសេរី ដែលធ្វើឱ្យដំណើរការគ្រប់គ្រងកាន់តែមានតម្លាភាព មានភាពរហ័ស និងកាន់តែមានប្រសិទ្ធភាព។ ថ្នាលទាំងនេះអនុញ្ញាតឱ្យប្រជាជនតាមដានការចំណាយរបស់រដ្ឋាភិបាល ចូលមើលទិន្នន័យគោលនយោបាយ និងត្រួតពិនិត្យសេវាសាធារណៈ រួមទាំងទិន្នន័យពាក់ព័ន្ធផ្សេងទៀតផងដែរ។




- **Real-Time Monitoring and Reporting Systems៖** បច្ចេកវិទ្យាកំព្យូទ័រក្លោដ គឺជាឧទាហរណ៍មួយនៃបច្ចេកវិទ្យាឌីជីថល ដែលអាចនាំឱ្យមានការធ្វើបច្ចុប្បន្នភាពបានទាន់ពេលវេលានិងគ្រប់ទីកន្លែង និងអាចតាមដានការចំណាយសាធារណៈ និងការអនុវត្តគោលនយោបាយផងដែរ។ ប្រព័ន្ធទាំងនេះបង្កើនតម្លាភាពនៃប្រតិបត្តិការរបស់រដ្ឋាភិបាល ដោយផ្តល់នូវភាពងាយស្រួលក្នុងការចងក្រង និងរក្សាទុកឯកសារ ទិន្នន័យ និងសកម្មភាពសំខាន់ៗ ព្រមទាំងផ្តល់ភាពងាយស្រួលដល់ការធ្វើការងារដោយបានកាត់បន្ថយទាំងពេលវេលា និងថវិកា។



- **Automated Systems and Blockchain៖** បច្ចេកវិទ្យា ដូចជា Blockchain បានផ្តល់នូវកំណត់ត្រាប្រតិបត្តិការមិនអាចផ្លាស់ប្តូរបាន ដែលធានាថាសកម្មភាពរបស់រដ្ឋាភិបាលអាចត្រូវបានតាមដាន និងមិនមានការកែប្រែ ព្រមទាំងបានបង្ហាញពីភាពស្អាតស្អំ និងភាពទំនើបនៃការគ្រប់គ្រង និងធ្វើការរបស់រដ្ឋាភិបាលផងដែរ។ បច្ចេកវិទ្យា Blockchain បង្កើនកម្រិតនៃការទទួលខុសត្រូវរបស់មន្ត្រីបម្រើការងារ ដែលនឹងជួយកាត់បន្ថយអំពើពុករលួយ និងលើកកម្ពស់អភិបាលកិច្ចល្អ។



- **Real-Time Performance Monitoring with AI៖** បញ្ញាសិប្បនិម្មិត និងការវិភាគទិន្នន័យអនុញ្ញាតឱ្យរដ្ឋាភិបាលអាចតាមដានការអនុវត្តគម្រោងសាធារណៈ និងវាយតម្លៃប្រសិទ្ធភាពគោលនយោបាយក្នុងពេលវេលាជាក់ស្តែង។ ការត្រួតពិនិត្យ និងតាមដាននេះបានផ្តល់ឱ្យនូវការសម្រេចចិត្តកាន់តែមានប្រសិទ្ធភាព។ **Digital Platforms៖** ប្រព័ន្ធផ្សព្វផ្សាយសង្គម, ញត្តិឌីជីថល (Digital Petitions) និងថ្នាលអនុញ្ញាតឱ្យប្រជាពលរដ្ឋអាចចូលរួមបានយ៉ាងសកម្មក្នុងការងារអភិបាលកិច្ច ដោយប្រជាពលរដ្ឋអាចរាយការណ៍ពីបញ្ហានានា ដែលធ្វើឱ្យមន្ត្រីកាន់តែមានការទទួលខុសត្រូវ ព្រមទាំងអាចជះឥទ្ធិពលដល់ការសម្រេចចិត្តគោលនយោបាយរបស់រដ្ឋាភិបាលផលដែរ។



## III. ឱកាស និងបញ្ហាប្រឈមនៃអភិបាលកិច្ចឌីជីថល

អភិបាលកិច្ចឌីជីថលបាននិងកំពុងផ្លាស់ប្ដូររបៀបដែលសង្គមដំណើរការ ដោយបានតភ្ជាប់ទំនាក់ទំនងរវាងប្រជាពលរដ្ឋ រដ្ឋាភិបាល និងសេវាសាធារណៈ ឱ្យបានលឿន ប្រសើរ និងមានតម្លាភាពជាងមុន។ នៅពេលដែលបច្ចេកវិទ្យាត្រូវបានដាក់បញ្ចូលទៅក្នុងជីវិតប្រចាំថ្ងៃរបស់មនុស្ស រដ្ឋាភិបាលក៏ត្រូវងាកទៅរកការប្រើប្រាស់ឧបករណ៍ឌីជីថលឱ្យកាន់តែច្រើនផងដែរ ដើម្បីអាចគ្រប់គ្រងព័ត៌មាន ផ្ដល់សេវាកម្ម និងចូលរួមជាមួយសហគមន៍បានពេញលេញ។ ការផ្លាស់ប្ដូរទាំងនេះបានបើកទ្វារថ្មីឆ្ពោះទៅរកការចូលរួម បង្កើនប្រសិទ្ធភាព និងការទទួលខុសត្រូវកាន់តែច្រើននៅក្នុងអភិបាលកិច្ច។ ក្នុងពេលជាមួយគ្នានេះ ការផ្លាស់ប្ដូរទៅជាប្រព័ន្ធឌីជីថលនេះក៏បាននាំមកនូវបញ្ហាប្រឈមថ្មីៗជាច្រើន ចាប់តាំងពីហានិភ័យសន្តិសុខសាយប័រ និងហានិភ័យទិន្នន័យឯកជនភាព រហូតដល់បញ្ហាគម្លាតឌីជីថល និងអក្ខរកម្មឌីជីថលជាដើម។ ការយល់ដឹងឱកាស និងបញ្ហាប្រឈម គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ការកសាងអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព និងមានភាពធន់នៅក្នុងយុគសម័យឌីជីថល។

### ▶ ឱកាស

អភិបាលកិច្ចឌីជីថលនាំមកនូវឱកាសជាច្រើនក្នុងការផ្លាស់ប្ដូររបៀប ដែលរដ្ឋាភិបាលបម្រើ និងធ្វើទំនាក់ទំនងជាមួយប្រជាពលរដ្ឋ។ តាមរយៈការផ្លាស់ប្ដូរសេវាកម្មតាមអ៊ីនធឺណិត ប្រជាជនអាចបំពេញកិច្ចការប្រចាំថ្ងៃ ដូចជា ការដាក់ពាក្យសុំអាជ្ញាប័ណ្ណ ការបង់ពន្ធ ឬការទទួលបានអត្ថប្រយោជន៍សង្គមជាច្រើនបានយ៉ាងឆាប់រហ័ស និងងាយស្រួល ដោយមិនចាំបាច់ធ្វើដំណើរ ឬរង់ចាំជាជួរទៀតនោះឡើយ។ ការផ្លាស់ប្ដូរនេះក៏អនុញ្ញាតឱ្យរដ្ឋាភិបាលប្រមូល និងប្រើប្រាស់ទិន្នន័យកាន់តែមានប្រសិទ្ធភាព ដោយជួយមន្ត្រីឱ្យយល់អំពីតម្រូវការសាធារណៈ រៀបចំផែនការគោលនយោបាយបានកាន់តែចំគោលដៅ និងឆ្លើយតបបានរហ័សចំពោះបញ្ហាប្រឈម ដូចជា វិបត្តិសុខភាព ឬគ្រោះធម្មជាតិជាដើម។ នៅពេលដែលដំណើរការជាច្រើនប្រែក្លាយជាទម្រង់ឌីជីថល តម្លាភាពនឹងកាន់តែប្រសើរឡើងដោយហេតុថាប្រជាពលរដ្ឋអាចចូលមើលព័ត៌មានអំពីការរៀបចំគោលនយោបាយ, ការចំណាយ, ការបង្កើតគម្រោង និងការសម្រេចចិត្តនានារបស់រដ្ឋាភិបាលបានយ៉ាងងាយ ដែលនេះជួយកសាងទំនុកចិត្ត និងកាត់បន្ថយអំពើពុករលួយផងដែរ។ ក្នុងពេលជាមួយគ្នានេះ ថ្នាលឌីជីថលក៏ផ្ដល់ឱ្យប្រជាពលរដ្ឋនូវការបញ្ចេញសម្លេងជាសាធារណៈ ដោយអនុញ្ញាតឱ្យមានការពិគ្រោះយោបល់តាមប្រព័ន្ធអ៊ីនធឺណិត និងផ្ដល់មតិកែលម្អ។ បន្ថែមពីនេះ ស្វ័យប្រវត្តិកម្ម និងបញ្ញាសិប្បនិម្មិតបាននិងកំពុងពង្រឹងប្រសិទ្ធភាពអភិបាលកិច្ចបន្ថែម ដោយការដោះស្រាយកិច្ចការដដែលៗ ដែលផ្ដល់អាទិភាពដល់បុគ្គលិកក្នុងការផ្ដោតលើការកែលម្អសេវាសាធារណៈ។ អភិបាលកិច្ចឌីជីថលនឹងលើកកម្ពស់ការចូលរួមរបស់ជនងាយរងគ្រោះ ដែលជារឿយៗត្រូវបានគេទុកចោល ដូចជា អ្នកដែលរស់នៅតំបន់ដាច់ស្រយាល, ស្ត្រី, ជនមានពិការភាព ដោយធានាថាមនុស្សគ្រប់គ្នាមានសិទ្ធិចូលប្រើប្រាស់ព័ត៌មាន និងការគាំទ្រស្មើៗគ្នា។

## បញ្ហាប្រឈម

### គម្លាតឌីជីថល

បញ្ហាគម្លាតឌីជីថលនៅតែជាបញ្ហាប្រឈមមួយសំខាន់ ដែលបានរាំងស្ទះដល់ការជំរុញអភិបាលកិច្ចឌីជីថល។ ប្រជាជននៅតាមតំបន់ដាច់ស្រយាល, ជនមានពិការភាព ឬជនជាតិភាគតិចក្តី គឺសុទ្ធសឹងតែមានភាពលំបាកក្នុងការប្រើប្រាស់បច្ចេកវិទ្យា ដែលជាហេតុធ្វើឱ្យការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការជំរុញអភិបាលកិច្ចឌីជីថលមានភាពខ្វះខាត និងមិនអាចបំពេញគ្រប់តម្រូវការ។ ជាមួយគ្នានេះ បើគ្មានការចូលប្រើប្រាស់បច្ចេកវិទ្យាឱ្យបានពេញលេញនោះទេ សហគមន៍ដែលងាយរងគ្រោះមិនអាចទទួលបានអត្ថប្រយោជន៍ពីអភិបាលកិច្ចឌីជីថលបានដែរ។ ជាក់ស្តែង នៅក្នុងប្រទេសឥណ្ឌា បើទោះបីជាមានការអភិវឌ្ឍយ៉ាងណាក៏ដោយ ក៏ប្រទេសនេះនៅតែប្រឈមនឹងបញ្ហាគម្លាតឌីជីថល ជាពិសេសនៅតំបន់ជនបទ ដែលការចូលប្រើប្រាស់អ៊ីនធឺណិតនៅមានកម្រិត ធ្វើឱ្យមានរារាំងដល់ការចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងអភិបាលកិច្ច។

### សន្តិសុខសាយប័រ និងឯកជនភាពទិន្នន័យ

ការផ្លាស់ប្តូរទៅជាប្រព័ន្ធឌីជីថលបានបង្កើនភាពងាយរងគ្រោះទាក់ទងនឹងការវាយប្រហារតាមអ៊ីនធឺណិត ការលួចទិន្នន័យ និងការលួចអត្តសញ្ញាណជាដើម ដោយហេតុថា ទិន្នន័យផ្ទាល់ខ្លួនមួយចំនួននឹងត្រូវបានចុះនៅលើប្រព័ន្ធអនឡាញ តាមរយៈគេហទំព័ររបស់រដ្ឋាភិបាល ហើយប្រសិនបើប្រព័ន្ធត្រូវបានវាយប្រហារ ឬលួចចូលនោះ ទិន្នន័យទាំងនោះនឹងត្រូវបានលួចដូចគ្នា។ អាស្រ័យហេតុនេះ ការធានាសុវត្ថិភាពនៃទិន្នន័យរសើប និងការការពារ ឯកជនភាពរបស់ប្រជាពលរដ្ឋ គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការរក្សាទំនុកចិត្តលើអភិបាលកិច្ចឌីជីថល។ ជាក់ស្តែង គណៈកម្មការរៀបចំការបោះឆ្នោតហ្វីលីពីន បានរងការលួចទិន្នន័យសំខាន់ៗនៅក្នុងឆ្នាំ២០១៧ ដោយត្រូវបានគេលាតត្រដាងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកបោះឆ្នោតរាប់លាននាក់ ដែលនេះបានបង្ហាញពីភាពចាំបាច់នៃសន្តិសុខសាយប័រនៅក្នុងអភិបាលកិច្ចឌីជីថល។

### សីលធម៌ក្នុងការប្រើប្រាស់ទិន្នន័យ

ការប្រើប្រាស់ទិន្នន័យទូលំទូលាយពេក អាចនាំឱ្យមានការប្រើប្រាស់ខុស ដែលបង្កើនក្តីបារម្ភផ្នែកសីលធម៌លើឯកជនភាព។ ការធ្វើឱ្យមានតុល្យភាពរវាងតម្លាភាព និងសិទ្ធិបុគ្គល គឺពិតជាមានសារៈសំខាន់ណាស់។ ជាក់ស្តែង ប្រព័ន្ធឥណទានសង្គមរបស់ប្រទេសចិនបានលើកឡើងពីក្តីបារម្ភផ្នែកក្រមសីលធម៌លើការប្រើប្រាស់ទិន្នន័យពលរដ្ឋរបស់រដ្ឋាភិបាលសម្រាប់ការឃ្លាំមើល និងការគ្រប់គ្រង ដែលនេះចាំបាច់តម្រូវឱ្យមានគោលការណ៍ណែនាំសីលធម៌ក្នុងការប្រើប្រាស់ទិន្នន័យឱ្យបានច្បាស់លាស់។

## IV. ករណីសិក្សា៖

### ប្រទេសកម្ពុជា

សម្រាប់កម្ពុជា អភិបាលកិច្ចល្អ គឺជាគន្លឹះមួយយ៉ាងចាំបាច់ ក្នុងការធ្វើឱ្យប្រសើរឡើង នូវការអភិវឌ្ឍសង្គម ដែលនាំមកនូវសុខដុមភាពជូនប្រជាជន តាមរយៈកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌សង្គម។ អភិបាលកិច្ចមានការវិវត្តទៅតាមសម័យកាល រហូតដល់យុគសម័យឌីជីថលនាពេលបច្ចុប្បន្ន បានវិវត្តន៍ខ្លួនទៅជាអភិបាលកិច្ចឌីជីថល។ នៅក្នុងបរិការណ៍កម្ពុជា រាជរដ្ឋាភិបាលជាតួអង្គសំខាន់ ដែលនឹងនាំឱ្យមានការស្រូបយក និងការធ្វើបរិវត្តកម្មឌីជីថលក្នុងសង្គមជាតិទាំងមូលអាចប្រព្រឹត្តទៅបានរលូន និងមិនមានហានិភ័យ ដែលដំបូងត្រូវធ្វើបរិវត្តកម្មឌីជីថលប្រព័ន្ធអភិបាលកិច្ចខ្លួនឯងជាមុនសិន ប៉ុន្តែអភិបាលកិច្ចឌីជីថលមានវិសាលភាពធំទូលាយ ដែលមិនកំណត់ត្រឹមរាជរដ្ឋាភិបាលនោះទេ សូម្បីតែវិស័យឯកជនក៏គិតគូរលើការគ្រប់គ្រងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការជំរុញនវានុវត្តន៍នៅក្នុងស្ថាប័នខ្លួនប្រកបដោយការទទួលខុសត្រូវ។ ប្រទេសជាច្រើនបាននិងកំពុងអនុវត្តអភិបាលកិច្ចឌីជីថល ហើយកម្ពុជា ក៏មិនខុសពីប្រទេសទាំងនោះ ក៏ព្យាយាមជំរុញអភិបាលកិច្ចឌីជីថលនៅកម្ពុជាផងដែរ។ ជាក់ស្តែង កម្ពុជាមានការវិវត្តគួរឱ្យកត់សម្គាល់ទាក់ទងនឹងអភិបាលកិច្ចឌីជីថល តាមរយៈការដាក់ចេញនូវវិធានការ និងរៀបចំនូវលិខិតបទដ្ឋានគតិយុត្តនានាជាច្រើន ដើម្បីជំរុញបរិវត្តកម្មឌីជីថល ស្របពេលដែលអាចគ្រប់គ្រងហានិភ័យនានាបាន។

ខាងក្រោមនេះ ជាកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ ក្នុងការជំរុញអភិបាលកិច្ចឌីជីថល៖

#### ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥

រាជរដ្ឋាភិបាលបានដាក់ចេញនូវ **ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥** ជាមួយចក្ខុវិស័យច្បាស់លាស់មួយគឺ "ការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និងបរិវត្តកម្មឌីជីថល នៅក្នុងគ្រប់តួអង្គសង្គម ទាំងរដ្ឋ ទាំងពលរដ្ឋ និងទាំងធុរជន ដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខុមាលភាពសង្គម តាមគន្លងប្រក្រតីភាពថ្មី"។ ដើម្បីកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាតាមចក្ខុវិស័យនេះ ក្របខណ្ឌគោលនយោបាយនេះបានកំណត់យកគោលដៅចម្បងចំនួន ៥ រួមមាន៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ, ការកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធឌីជីថល, ការកសាងពលរដ្ឋឌីជីថល, ការកសាងរដ្ឋាភិបាលឌីជីថល និងការជំរុញធុរកិច្ចឌីជីថល។ ក្នុងនោះ មានការអនុវត្តវិធានការជាក់លាក់មួយចំនួន  ទាក់ទងនឹងវិធានការគោលនយោបាយផ្នែកសន្តិសុខសាយប័រ ដោយគិតគូររៀបចំស្តង់ដា ក្របខ័ណ្ឌបច្ចេកទេស និងនីតិវិធីនៃការឆ្លើយតប ដើម្បីជាមូលដ្ឋានសម្រាប់ការអនុវត្ត និងការប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយសន្តិសុខ និងសុវត្ថិភាព ព្រមទាំងវិធានការក្នុងការរៀបចំពង្រឹងអភិបាលកិច្ចផ្អែកលើទិន្នន័យ ដែលនឹងជួយជំរុញ និងលើកកម្ពស់តួនាទីរបស់វិស័យសាធារណៈ។

## ▶ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១

រាជរដ្ឋាភិបាលបានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅការពារ ថែរក្សា និងពូនជ្រំសមិទ្ធផលជាតិ, លើកកម្ពស់កិត្យានុភាពជាតិឱ្យខ្ពស់ត្រដែត, ជំរុញសម្ទុះនៃកំណើនសេដ្ឋកិច្ច និងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបាន ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដោយបានកំណត់យកអាទិភាពគន្លឹះចំនួន ៥ រួមមាន មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ដែលជាអាទិភាពគន្លឹះបន្ថែមថ្មី។ រាជរដ្ឋាភិបាលបានចាត់ទុកបច្ចេកវិទ្យាឌីជីថលជាកាតាលីករថ្មីដ៏មានសារៈសំខាន់ ដែលមានសក្តានុពលភាព និងកាលានុវត្តភាពក្នុងការជំរុញកំណើនផលិតភាពសេដ្ឋកិច្ច និងសង្គម ក៏ដូចជាប្រសិទ្ធភាពនៃការងាររដ្ឋបាល។ ក្នុងនោះ មួយក្នុងចំណោមគោលដៅយុទ្ធសាស្ត្រ គឺបន្តពង្រឹងសមត្ថភាពអភិបាលកិច្ចទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងការបង្កើនប្រសិទ្ធភាព និងតម្លាភាព នៃអភិបាលកិច្ចវិស័យឯកជន និងធុរកិច្ច តាមរយៈការជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការធ្វើអភិបាលកិច្ច។

## ▶ គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥

រដ្ឋាភិបាលកម្ពុជា បានចាត់ទុកការកសាងរដ្ឋាភិបាលឌីជីថលគឺជារបៀបវារៈសំខាន់មួយក្នុងការជំរុញកំណែទម្រង់ក្រសួង ស្ថាប័ន និងរដ្ឋាភិបាលថ្នាក់ក្រោមជាតិ និងការបង្កើតនូវបរិយាកាសអំណោយផលដល់ការជំរុញការវិនិយោគ និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយបរិយាបន្ន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវ **គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥** ក្នុងគោលបំណងកសាងរដ្ឋាភិបាលឆ្លាត ដោយឈរលើមូលដ្ឋាននៃការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យាជាប្រព័ន្ធអេកូឡូស៊ី សម្រាប់ការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ច និងការកែទម្រង់ប្រកបដោយតម្លាភាព និងភាពជឿទុកចិត្ត ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមឌីជីថលប្រកបដោយបរិយាបន្ន។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានដាក់ចេញគោលដៅជាយុទ្ធសាស្ត្រចំនួន ៤ និងយុទ្ធសាស្ត្រចំនួន ១០ ដោយក្នុងចំណោមនោះគោលដៅជាយុទ្ធសាស្ត្រមួយ គឺការកសាងអភិបាលកិច្ច និងសេវាសាធារណៈឌីជីថល ដែលមានយុទ្ធសាស្ត្រចំនួន ២ គឺ ទី១. ការរៀបចំអភិបាលកិច្ចរដ្ឋាភិបាលឌីជីថល និងទី២. ការធ្វើបរិវត្តកម្មរដ្ឋាភិបាលឌីជីថល និងសេវាសាធារណៈ។

## ▶ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ បានគិតគូរលើនិន្នាការតំបន់ និងសកល ដែលជាកាលានុវត្តភាព ហានិភ័យ និងបញ្ហាប្រឈម ដែលអាចមានកម្មវិបាកលើកម្ពុជា តាមរយៈការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ច ដែលកើតឡើងពីការប្រណាំងប្រជែងឥទ្ធិពលរបស់ប្រទេសមហាអំណាច និងទំនោរទៅរកការកើនឡើងនៃការគាំពារនិយម ការប្រែប្រួលនិម្មាបនកម្មសេដ្ឋកិច្ចសកល ការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ជាពិសេសឌីជីថលូបនីយកម្ម និង

ការប្រែប្រួលអាកាសធាតុ ដែលអាចមានកម្មវិបាកលើដំណើរនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ គឺជាផែនទីបង្ហាញផ្លូវដល់គ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ និងជាឧបករណ៍សម្រាប់អនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** និងវិធានការគន្លឹះទាំង ៥ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច បន្តបង្កើតការងារ បែងចែកផ្លែផ្កានៃការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌ ធានានូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និងរក្សាចីរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម តាមរយៈការពង្រឹង លើកកម្ពស់ ធ្វើទំនើបកម្ម និងបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចនៅគ្រប់ផ្នែក ជាពិសេសការពង្រឹងអភិបាលកិច្ចវិស័យឯកជន និងធុរកិច្ច។

### ▶ គណៈកម្មាធិការសន្តិសុខឌីជីថល

រាជរដ្ឋាភិបាលក៏បានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការប្រយុទ្ធប្រឆាំងនឹងការវាយប្រហារតាមអ៊ីនធឺណិត តាមរយៈការបង្កើតនូវ **«គណៈកម្មាធិការសន្តិសុខឌីជីថល»** ដែលអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសន្តិសុខឌីជីថល ត្រូវបានដាក់ចេញកាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៤។ ការបង្កើតគណៈកម្មាធិការសន្តិសុខឌីជីថលនេះធ្វើឡើងក្នុងគោលបំណងធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការបំពេញមុខងារ ដឹកនាំ សម្របសម្រួល និងជំរុញការគ្រប់គ្រងសន្តិសុខឌីជីថលលើការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីការពារអត្ថប្រយោជន៍របស់គ្រប់តួអង្គសង្គមទប់ទល់នឹងការវាយប្រហារគ្រប់រូបភាព ឆ្លើយតបគ្រប់ផ្នែកទាំងបច្ចេកទេស និងកម្លាំងពាក់ព័ន្ធនឹងការធានា និងការពារសន្តិសុខឌីជីថល។

### ▶ ការរៀបចំលិខិតបទដ្ឋានគតិយុត្ត

ក្រៅពីការជំរុញបរិវត្តកម្មឌីជីថលនៅកម្ពុជា រាជរដ្ឋាភិបាលក៏កំពុងរៀបចំសេចក្តីព្រាងច្បាប់ និងដាក់ចេញអនុក្រឹត្យនានាផងដែរ សំដៅការលើកកម្ពស់វិធានការសុវត្ថិភាពទិន្នន័យ ដូចជា សេចក្តីព្រាងច្បាប់ការពារទិន្នន័យផ្ទាល់ខ្លួន, សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ និងអនុក្រឹត្យ ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គលជាដើម។

### ▶ ការចូលរួមពីវិស័យឯកជន

ក្រៅពីនេះ វិស័យឯកជន ក៏ជាកត្តាជំរុញសំខាន់មួយក្នុងការអនុវត្តអភិបាលកិច្ចឌីជីថល តាមរយៈការវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ, ការជំរុញបរិវត្តកម្មឌីជីថលនៅក្នុងស្ថាប័នរបស់ខ្លួន និងការវិនិយោគផ្សេងៗទៀតក្នុងការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសុវត្ថិភាពទិន្នន័យនៅកម្ពុជា។ ជាក់ស្តែង ធនាគារ ABA បានសហការជាមួយដៃគូបច្ចេកវិទ្យា ដូចជា SUSE ដើម្បីធ្វើស្វ័យប្រវត្តិកម្មប្រតិបត្តិការ និងរួមបញ្ចូលដំណោះស្រាយសុវត្ថិភាព ដូចជា SUSE Security ទៅក្នុងសេវាកម្មខ្នាតតូចរបស់ខ្លួន ដែលអាចបង្កើនការច្នៃប្រឌិតនៅក្នុងវិស័យធនាគារឌីជីថល ខណៈពេលដែលពង្រឹងការការពារប្រឆាំងនឹងការគំរាមកំហែងតាមអ៊ីនធឺណិត។

## V. សេចក្តីសន្និដ្ឋាន

សរុបមក អភិបាលកិច្ចឌីជីថលគឺជាប្រព័ន្ធគ្រប់គ្រងដ៏មានសារៈសំខាន់ក្នុងយុគសម័យឌីជីថល ដែលបានដើរតួនាទីជាចម្បងក្នុងការលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងការទទួលខុសត្រូវនៃការគ្រប់គ្រងសាធារណៈ។ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដូចជា ទិន្នន័យបើកចំហ បញ្ញាសិប្បនិម្មិត និងបច្ចេកវិទ្យាប្លុកឆេន បានជួយគាំទ្រដល់ដំណើរការសម្រេចចិត្តផ្អែកលើទិន្នន័យ និងការផ្តល់សេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបបានល្អប្រសើរចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តអភិបាលកិច្ចឌីជីថលនៅតែប្រឈមមុខនឹងបញ្ហាប្រឈមសំខាន់ៗ រួមមាន គម្លាតឌីជីថល ហានិភ័យសន្តិសុខសាយប័រ ភាពឯកជនភាពទិន្នន័យ និងបញ្ហាសីលធម៌ក្នុងការប្រើប្រាស់ទិន្នន័យ ដែលទាមទារឱ្យមានក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងយន្តការគ្រប់គ្រងដ៏រឹងមាំ។ សម្រាប់បរិបទកម្ពុជា រាជរដ្ឋាភិបាលបានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងច្បាស់លាស់ក្នុងការជំរុញអភិបាលកិច្ចឌីជីថល តាមរយៈការដាក់ចេញគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើន ដើម្បីគាំទ្រដល់ការកែទម្រង់រដ្ឋបាលសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាព។ ដូច្នេះ ការបន្តពង្រឹងសមត្ថភាពស្ថាប័ន ការអភិវឌ្ឍធនធានមនុស្ស និងការជំរុញការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ គឺជាកត្តាស្នូលក្នុងការធានាថា អភិបាលកិច្ចឌីជីថលអាចអនុវត្តបានយ៉ាងមានប្រសិទ្ធភាព សុវត្ថិភាព និងស្របតាមគោលការណ៍អភិបាលកិច្ចល្អ៕

## ឯកសារយោង


- What is Governance?, ចូលអានថ្ងៃទី១២ ខែមករា ឆ្នាំ២០២៦,https://www.cgi.org.uk/resources/factsheets/factsheets/what-is-governance/#:~:text=Governance%20is%20the%20framework%20by,for%20achieving%20sustainable%20business%20practices.
- Governance in the Digital Era: The Role of Technology in Enhancing Transparency and Accountability, ចេញផ្សាយថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៥, ចូលអានថ្ងៃទី៦ ខែមករា ឆ្នាំ២០២៦, https://medium.com/@riazleghari/governance-in-the-digital-era-the-role-of-technology-in-enhancing-transparency-and-accountability-78bd2ffe8208
- Digital governance, ចូលអានថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦, https://www.unesco.org/en/query-list/d/digital-governance#term-definition
- Digital governance, ចេញផ្សាយថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៥, ចូលអានថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦, https://www.good-governance.org.uk/publications/insights/digital-governance-101
- អត្ថបទ E-Governance: Origin, challenges, and prospects in the era of ICTs and artificial intelligence, ចេញផ្សាយខែមិថុនា ឆ្នាំ២០២៣, ចូលអានថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៦
- ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, ចេញផ្សាយខែឧសភា ឆ្នាំ២០២១, ចូលអានថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៦
- គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥, ចេញផ្សាយខែមករា ឆ្នាំ២០២២, ចូលអានថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៦
- យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១, ចេញផ្សាយខែសីហា ឆ្នាំ២០២៣, ចូលអានថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៦
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា, ចេញផ្សាយថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៥, ចូលអានថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៦
- អត្ថបទសិក្សា ស្ដីពី "សុវត្ថិភាពទិន្នន័យ", ចេញផ្សាយថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៥, ចូលអានថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៦
- ABA Bank teams up with SUSE to boost digital banking in Cambodia, ចេញផ្សាយថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៥, ចូលអានថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៦, https://www.frontier-enterprise.com/aba-bank-teams-up-with-suse-to-boost-digital-banking-in-cambodia/
- ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥, ចូលអានថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦
- Governance In The Digital Era: Three Pathways For The Future Of Public Policy And Administration, ចេញផ្សាយខែវិច្ឆិកា ឆ្នាំ២០២៤, ចូលអានថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២៦, https://sciencepolicy.ca/posts/governance-in-the-digital-era-three-pathways-for-the-future-of-public-policy-and-administration/

- *Alternative Futures for Digital Governance*, ចេញផ្សាយថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩, ចូលអានថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៦, *https://dl.acm.org/doi/abs/10.1145/3325112.3325238*


---

កម្ពុជា ៤.0 - Cambodia 4.0

www.cambodia4point0.org

កម្ពុជា ៤.0 Cambodia 4.0

cambodia_4.0

កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

Cambodia 4.0 Center